ក្រសួងបរិស្ថាន
លេខៈ ៥៨៨.សស.ណា ប.ស្ថ

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងជ្រើសរើសនិស្សិត ចូលបម្រើការងារ ជាមន្ត្រីរាជការ ក្នុងក្របខ័ណ្ឌ ក្រសួងបរិស្ថានសម្រាប់ ឆ្នាំ ២០១៥

ក្រសួងបរិស្ថាន មានកិត្តិយសសូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជន ឱ្យបានជ្រាបថា អនុវត្តតាមលិខិតលេខ ៩៨៣ មស.ក្រខ ចុះថ្ងៃទី០៧ ខែ មេសា ឆ្នាំ២០១៥ របស់ក្រសួងមុខងារសាធារណៈ ក្រសួងបរិស្ថាននឹងធ្វើការប្រឡងជ្រើសរើសសិស្ស និស្សិត ចូលបម្រើការងារជាមន្ត្រីរាជការក្នុងក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ គ្រប់គ្រងរដ្ឋបាល ក្រមការ លេខាធិការ នៅទីស្តីការក្រសួង សម្រាប់ឆ្នាំ២០១៥ ចំនួន៣៣កន្លែង។

## ១. លក្ខខណ្ឌសម្រាប់ជ្រើសរើស

បេក្ខជនត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១.១. ត្រូវមានសញ្ជាតិខ្មែរ

១.២. សម្រាប់ក្របខណ្ឌ"ក" និស្សិតដែលមានកម្រិតបណ្តុះបណ្តាលសញ្ញាបត្រកម្រិតបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ និងត្រូវមានអាយុមិនឱ្យលើសពី ៣០ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

១.៣. សម្រាប់ក្របខណ្ឌ"ខ" សិស្ស និស្សិតដែលមានកម្រិតបណ្តុះបណ្តាលសញ្ញាបត្រកម្រិតបរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូលឡើងទៅ និងត្រូវមានអាយុមិនឱ្យលើសពី ២៨ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

១.៤. សម្រាប់ក្របខណ្ឌ"គ" សិស្ស និស្សិតដែលមានកម្រិតបណ្តុះបណ្តាលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូលឡើងទៅ និងត្រូវមានអាយុចាប់ពី១៨ឆ្នាំ និងមិនឱ្យលើសពី ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រឡង។

## ២. មុខជំនាញ និងអង្គភាពដែលត្រូវបម្រើការងារ

| ល.រ | មុខជំនាញ ឯកទេស | ចំនួនជ្រើសរើស | ក្របខណ្ឌដែលត្រូវជ្រើសរើស | | |
|---|---|---|---|---|---|
| ក. អគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន ១០កន្លែង | | | ក | ខ | គ |
| ១. | ជំនាញ សារព័ត៌មាន | ២ | ២ | | |



អគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ ទន្លេបាសាក់ ចំការមន ភ្នំពេញ ទូរស័ព្ទៈ ០២៣ ២១៣ ៩០៨, ០២៣ ២២០ ៣៦៩ ទូរសារៈ ០២៣ ២១២ ៥៤០

| | | | | | |
|---|---|---|---|---|---|
| ២. | ជំនាញ វិទ្យាសាស្ត្រអប់រំ | ១ | ១ | | |
| ៣. | ជំនាញ គណនេយ្យ និងហិរញ្ញវត្ថុ | ១ | ១ | | |
| ៤. | ជំនាញ ព័ត៌មានវិទ្យា | ១ | ១ | | |
| ៥. | ជំនាញ បរិស្ថាន | ២ | ២ | | |
| ៦ | ជំនាញ អក្សរសាស្ត្រអង់គ្លេស | ១ | ១ | | |
| ៧ | ជំនាញ ពាណិជ្ជសាស្ត្រ | ១ | ១ | | |
| ៨ | ជំនាញ សំណង់ស៊ីវិល | ១ | ១ | | |
| **ខ. អគ្គនាយកដ្ឋានគាំពារបរិស្ថាន ០៧កន្លែង** | | | **ក** | **ខ** | **គ** |
| ១ | ជំនាញ បរិស្ថាន | ១ | ១ | | |
| ២ | ជំនាញ រដ្ឋបាលសាធារណៈ | ១ | ១ | | |
| ៣ | ជំនាញ គណនេយ្យ និងហិរញ្ញវត្ថុ | ១ | | ១ | |
| ៤ | ជំនាញ ជីវគីមីសាស្ត្រ | ២ | ២ | | |
| ៥ | ជំនាញ បច្ចេកទេសមន្ទីរពិសោធន៍ | ១ | | ១ | |
| ៦ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ១ | | | ១ |
| **គ. អគ្គនាយកដ្ឋានរដ្ឋបាល ការពារ និងអភិរក្ស ០៥កន្លែង** | | | **ក** | **ខ** | **គ** |
| ១ | ជំនាញ ព័ត៌មានវិទ្យា | ១ | ១ | | |
| ២ | ជំនាញ វិទ្យាសាស្ត្ររុក្ខកម្ម | ១ | ១ | | |
| ៣ | ជំនាញ វិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ១ | ១ | | |
| ៤ | ជំនាញ បុរាណវិទ្យា | ១ | ១ | | |
| ៥ | ជំនាញ ស្ថាបត្យកម្ម | ១ | ១ | | |
| **ឃ. អគ្គលេខាធិការដ្ឋានអភិវឌ្ឍន៍ដោយចីរភាព ០៤កន្លែង** | | | **ក** | **ខ** | **គ** |
| ១ | ជំនាញ បរិស្ថាន | ១ | ១ | | |
| ២ | ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ | ១ | ១ | | |
| ៣ | ជំនាញ វិទ្យាសាស្ត្ររុក្ខកម្ម | ១ | ១ | | |
| ៤ | ជំនាញ វិទ្យាសាស្ត្រកសិកម្ម និងអភិវឌ្ឍន៍ជនបទ | ១ | ១ | | |
| **ង. អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ០៧កន្លែង** | | | **ក** | **ខ** | **គ** |
| ១ | ជំនាញ នីតិសាស្ត្រ | ១ | ១ | | |

| | | | | | |
|---|---|---|---|---|---|
| ២ | ជំនាញ រដ្ឋបាលសាធារណៈ | ១ | ១ | | |
| ៣ | ជំនាញ គណនេយ្យ និងហិរញ្ញវត្ថុ | ១ | ១ | | |
| ៤ | ជំនាញ អគ្គីសនី ថាមពល និងទូរគមនាគមន៍ | ១ | ១ | | |
| ៥ | ជំនាញ ពាណិជ្ជសាស្ត្រ | ១ | ១ | | |
| ៦ | ជំនាញ សិល្បសាស្ត្រ | ១ | ១ | | |
| ៧ | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | ១ | | | ១ |
| | សរុប | ៣៣ | ២៩ | ២ | ២ |

## ៣. វិញ្ញាសាប្រឡង

៣.១. វិញ្ញាសា ៖

- វិញ្ញាសា ចំណេះដឹងទូទៅ (រយៈពេល ០២ ម៉ោង)
- វិញ្ញាសា ជំនាញឯកទេស (រយៈពេល ០២ ម៉ោង)
- វិញ្ញាសា ភាសាអង់គ្លេស (រយៈពេល ០១ម៉ោង ៣០នាទី)

## ៤. កាលបរិច្ឆេទប្រឡង

- ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៥

## ៥. មណ្ឌលប្រឡង

- ទីស្តីការក្រសួងបរិស្ថាន

## ៦. ការទទួលពាក្យ

ចាប់ផ្តើមទទួលពាក្យសុំសិទ្ធិប្រឡងរៀងរាល់ម៉ោងធ្វើការ នៅនាយកដ្ឋានធនធានមនុស្ស នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងបរិស្ថាន ដែលមានទីតាំងស្ថិតនៅអគារលេខ៤៨ មហាវិថីសម្តេចព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ ហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥

**បញ្ជាក់៖** - សិស្ស និស្សិតដែលមានបំណងដាក់ពាក្យសុំប្រឡង សូមចូលទៅគេហទំព័រ www.moe.gov.kh ដើម្បីទាញយកពាក្យសុំសិទ្ធិប្រឡង។

- បេក្ខជនត្រូវចូលខ្លួនមកដាក់ពាក្យ និងបង់កម្រៃសិទ្ធិប្រឡង ចំនួន៦០,០០០រៀល ដោយភ្ជាប់មកជាមួយនូវបង្កាន់ដៃទទួលពាក្យសុំសិទ្ធិប្រឡង និងឯកសារសម្គាល់អត្តសញ្ញាណ។

## ៧. បេក្ខជនត្រូវបំពេញសំណុំលិខិតក្នុងការដាក់ពាក្យប្រឡង រួមមាន៖

- ពាក្យសុំចុះឈ្មោះប្រឡងត្រូវមានបិទតែមប្រិយ៍ (២០០៛) ចំនួន ០១ច្បាប់
- សេចក្តីចម្លងសញ្ញាបត្រដោយមានបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច ចំនួន ០១ច្បាប់

(បញ្ជាក់ចំពោះសញ្ញាបត្របណ្ដោះអាសន្ន ឬលិខិតបញ្ជាក់ការសិក្សាត្រូវមានការបញ្ជាក់ពីគណៈកម្មាធិការវាយតម្លៃកម្រិតសញ្ញាបត្រ និងលិខិតបញ្ជាក់ការសិក្សា)

- ជីវប្រវត្តិសង្ខេបមានបិទរូបថត (៤ x ៦) ចំនួន ០១ច្បាប់
- សេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត ចំនួន ០១ច្បាប់
- សាលាកបត្រឯកត្តជន ចំនួន ០១ច្បាប់
- កិច្ចសន្យាបម្រើការងារក្រសួង ចំនួន ០១ច្បាប់
- បង្កាន់ដៃបង់ប្រាក់សុំសិទ្ធិប្រឡង ចំនួន ០១ច្បាប់
- រូបថតថ្មី ៤ x ៦ ថតចំពីមុខ ចំនួន០២សន្លឹក

**សេចក្ដីបញ្ជាក់៖**

- បេក្ខជន ជាជនពិការ និងស្ត្រី ដែលមានសមត្ថភាពសមស្រប ត្រូវបានផ្ដល់អាទិភាព
- បេក្ខជន ត្រូវសរសេរបំពេញបែបបទសុំសិទ្ធិប្រឡងចុះហត្ថលេខា និងមកដាក់ពាក្យដោយខ្លួនឯងផ្ទាល់
- បេក្ខជនត្រូវទៅធ្វើលិខិតបញ្ជាក់ពីសុខភាព នៅក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំពោះលិខិតថ្កោលទោស បេក្ខជនត្រូវប្រគល់ជូនក្រសួងក្រោយពីប្រឡងជាប់ជាស្ថាពរ។

**៨. ព័ត៌មានបន្ថែម**

សម្រាប់ព័ត៌មានលម្អិត សូមមកទាក់ទងនៅនាយកដ្ឋានធនធានមនុស្សនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ។

អាស្រ័យហេតុនេះ សូមនិស្សិត និងសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

កន្លែងទទួល៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង-ស្ថាប័ន សាលារាជធានី-ខេត្ត
- គ្រប់អង្គភាពចំណុះក្រសួងបរិស្ថាន
- ឯកសារ កាលប្បវត្តិ